# គោលការណ៍ជាមូលដ្ឋានស្ដីពី ការប្រើប្រាស់កំលាំង និងអាវុធ ដោយមន្ត្រីប្រតិបត្តិច្បាប់

# BASIC PRINCIPLES ON THE USE OF FORCE AND FIREARMS BY LAW ENFORCEMENT OFFICIALS

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

ចែកជូនដោយឥតគិតថ្លៃ

# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct for Law Enforcement Officials

*ត្រូវបានអនុម័តដោយសេចក្ដីសំរេចរបស់មហាសន្និបាត*
*អង្គការសហប្រជាជាតិ លេខ៣៤/១៦៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩*

## មាត្រា ១

ក្នុងការបំរើសហគមន៏ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក-ពាក្យថា "មន្ត្រីប្រតិបត្តិច្បាប់" សំដៅដល់មន្ត្រីច្បាប់ទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវបានជ្រើសតាំង

ក្តី ដែលប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុង-ការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋក្តី មន្ត្រីទាំងឡាយ ដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេស នូវការផ្តល់សេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច សង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះភ្លាម១ ។

ឃ- បញ្ញត្តិនេះមានគោលដៅគ្របដណ្តប់ មិនត្រឹមតែអំពើទាំងអស់ដែលហឹង្សា សាហាវព្រៃផ្សៃ និងគ្រោះ

ផ្ទាក់ដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងមានវិសាលភាព ដល់ការហាមឃាត់ទាំងស្រុង ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។

## មាត្រា ២

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងរក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប ។

## អត្ថាធិប្បាយ :

ក- សិទ្ធិមនុស្សដូចមានចែងខាងលើត្រូវបានកំណត់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុង-ចំណោមលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ មានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការ

ការពារជនគ្រប់រូបពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបនិងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មអាប៉ាថេដ អនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោស និងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ-សេចក្តីអត្ថាធិប្បាយជាតិលើបញ្ញត្តិនេះ គួរចង្អុលបង្ហាញពីបទបញ្ញត្តិជាតិ ឬតំបន់ ដែលបានកំណត់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់ អាចប្រើប្រាស់កំលាំងបានតែក្នុងករណីណាដែលចាំបាច់បំផុត និងស្ថិតក្នុងវិសាលភាពតម្រូវសំរាប់តែការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់ គួរតែជាករណីលើកលែង។ នេះមានន័យថា មន្ត្រីប្រតិបត្តិច្បាប់អាចត្រូវបានអនុញ្ញាតិឱ្យប្រើកំលាំងបាន តែក្នុងកាលៈទេសៈចាំបាច់សមហេតុផលដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ឬដើម្បីជួយដល់ការចាប់ខ្លួនជនល្មើសឬជនសង្ស័យតាមច្បាប់ ដោយគ្មានការប្រើកំលាំងណាមួយហួសពីនេះ ត្រូវបានអនុញ្ញាតឱ្យប្រើនោះទេ។

ខ- តាមធម្មតា ច្បាប់ជាតិដាក់កំហិតយ៉ាងតឹងរឹង ដល់មន្ត្រីប្រតិបត្តិច្បាប់ ក្នុងការប្រើប្រាស់កំលាំង ស្របតាមគោលការណ៍សមាមាត្រ ។ នេះក៏ជាប្រការត្រូវយល់ថា គោលការណ៍ជាតិនៃសមាមាត្រនេះ ត្រូវតែគោរពតាមក្នុងការបកស្រាយបញ្ញត្តិនេះ ។ គ្មានករណីណាមួយដែលបញ្ញត្តិនេះ ត្រូវបានបកស្រាយ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំងដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយនោះទេ ។

គ-ការប្រើប្រាស់អាវុធត្រូវបានចាត់ទុកថាជាវិធានការមួយហួសហេតុ។ មន្ត្រីប្រតិបត្តិច្បាប់ គួរប្រើគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដោយជៀសវាងមិនប្រើអាវុធ ជាពិសេសទៅលើកុមារ។ ជាទូទៅ ការប្រើអាវុធ ត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ហើយការចាត់វិធានការនេះមិនបានធ្ងន់ល្មម នឹងបញ្ឈប់ ឬចាប់ខ្លួនជនល្មើសនោះបាន។

ពេលណាដែលមានការបាញ់កាំភ្លើង ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

បញ្ហានានាដែលមានចរិតជាការសំងាត់ ឋិតក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ ត្រូវតែរក្សាជាការសំងាត់ លើកលែងតែមានការតម្រូវយ៉ាងតឹងរឹងក្នុងការបំពេញភារកិច្ច ឬតម្រូវការស្វែងរកយុត្តិធម៌ ប្រសិនបើមិនដូច្នេះ ការសំងាត់នេះមិនអាចទំលាយបានឡើយ ។

***អត្ថាធិប្បាយ :***

តាមចរិកលក្ខណៈនៃការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលព័ត៌មាននានា ដែលអាចទាក់ទងដល់ជីវិតឯកជន ឬដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍ និងជាពិសេសដល់កិត្តិយសអ្នកដទៃ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការការពារ និងការប្រើប្រាស់ព័ត៌

មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបាន តែក្នុង-ការបំពេញភារកិច្ច ឬបំរើឱ្យតម្រូវការយុត្តិធម៌តែប៉ុណ្ណោះ។ ការលាតត្រដាងព័ត៌មានបែបនេះ សំរាប់គោលបំណងអ្វីផ្សេងពីនេះ គឺជាការមិនត្រឹមត្រូវទាល់តែសោះ។

## មាត្រា ៥

គ្មានមន្ត្រីប្រតិបត្តិច្បាប់ណាអាចប្រព្រឹត្ត ញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬដាក់ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬក៏មិនត្រូវយកបទបញ្ជាថ្នាក់លើ ឬកាលៈទេសៈពិសេស ដូចជា ស្ថានភាពមានសង្គ្រាម ឬការគំរាមធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬស្ថានភាពគ្រាអាសន្នទូទៅដទៃទៀត មកធ្វើជាយុត្តិកម្មដល់ការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ ដកចេញពីសេចក្តីប្រកាសជាសកលស្តីពីកិច្ចការពារបុគ្គលគ្រប់រូបពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយមានខ្លឹមសារថា "អំពើបែបនេះ គឺជាអំពើល្មើសមួយចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវផ្តន្ទាទោសដោយសារថានេះគឺជាការបដិសេធពីគោលបំណងនៃធម្មនុញ្ញសហប្រជាជាតិ ហើយក៏ជាការរំលោភបំពានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត។

ខ- សេចក្តីប្រកាសនេះ ឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ និងការរងទុក្ខយ៉ាងធ្ងន់ធ្ងរ ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលបង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីសាធារណៈ ទៅលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតិយជនណាម្នាក់ ផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត។ នេះមិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតពីការដាក់ទណ្ឌកម្មស្របច្បាប់ក្នុងករិតមួយ ដែលស្របតាមបញ្ញត្តិដែលមានចែងក្នុងបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោសនោះឡើយ"។

គ- ពាក្យ "ការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតអង្គការសហប្រជាជាតិ មិនទាន់បានឱ្យនិយមន័យនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែត្រូវបានបកស្រាយយ៉ាងណា ដើម្បី

ពង្រីកការការពារឱ្យបានទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងនឹងការរំលោភបំពានគ្រប់យ៉ាង មិនថាផ្លូវកាយ ឬ ផ្លូវចិត្តឡើយ ។

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់ត្រូវធានាឱ្យបាននូវការការពារ ពេញលេញ ដល់សុខភាពរបស់ជនដែលឋិតក្នុងការឃុំខ្លួន របស់ខ្លួន ជាពិសេស ត្រូវចាត់វិធានការភ្លាមៗ ដើម្បីធានា ឱ្យមានការយកចិត្តទុកដាក់ដល់សុខភាព តាមការចាំបាច់ ។

### *អត្ថាធិប្បាយ :*

ក- "ការយកចិត្តទុកដាក់សុខភាព " សំដៅដល់ ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុង នោះមានគ្រូពេទ្យជំនាញ និងគ្រូពេទ្យជំនួយ ត្រូវតែប្រចាំ-ការជានិច្ច ដើម្បីឆ្លើយតបតាមតម្រូវការ ឬការស្នើសុំ ។

ខ- ប្រសិនបើបុគ្គលិកសុខាភិបាលចាំបាច់ ត្រូវចូល

រួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ នោះមន្ត្រីប្រតិបត្តិច្បាប់ ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលិកសុខាភិបាលនេះ នៅពេលដែលពួកគាត់ផ្តល់យោបល់ថាត្រូវផ្តល់ការព្យាបាលឱ្យបានសមរម្យ ដល់ជនដែលនៅក្នុងឃុំតាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាលដែលមិនចិតក្នុងកិច្ចប្រតិបត្តិការ របស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ-មន្ត្រីប្រតិបត្តិច្បាប់ ក៏ត្រូវធានាឱ្យមានការយកចិត្តទុកដាក់សុខភាពដល់ជនរងគ្រោះ ដោយការរំលោភបំពានច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តអំពើរំលោភច្បាប់ផងដែរ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ ឱ្យបានខ្លាំងក្លា។

***អត្ថាធិប្បាយ :***

ក- អំពើពុករលួយ ក៏ដូចជាអំពើដទៃទៀតនៃការបំពានអំណាចដែរ មានវិសមត្ថភាពជាមួយនឹងវិជ្ជាជីវៈជាមន្ត្រីប្រតិបត្តិច្បាប់។ ច្បាប់ត្រូវយកមកអនុវត្តន៏ឱ្យបានពេញលេញចំពោះមន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយ ព្រោះថា រដ្ឋាភិបាលមិនអាចរំពឹងថា យកច្បាប់មកអនុវត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួនបានទេ ប្រសិនបើរដ្ឋាភិបាលមិនអាចអនុវត្ត ឬនឹងមិនអនុវត្តន៏ច្បាប់ឱ្យបានត្រឹមត្រូវ ទៅលើភ្នាក់ងារផ្ទាល់របស់ខ្លួន ឬក្នុងក្របខ័ណ្ឌស្ថាប័នខ្លួននោះ។

ខ- ទន្ទឹមនឹងនិយមន័យនៃពាក្យ "ពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិនោះ ពាក្យនេះក៏ត្រូវយល់ក្នុងន័យមួយគ្របដណ្តប់ផងដែរលើអំពើសកម្ម ឬអកម្មក្នុងការបំពេញភារកិច្ច ឬទាក់ទងនឹងភារកិច្ចណាមួយ ដែលពាក់ព័ន្ធនឹងការទាមទារ ឬទទួលយកអំណោយ ការសន្យា ឬរង្វាន់លើកទឹកចិត្តផ្សេងៗ ឬក៏ការទទួលយកដោយខុសនូវរបស់

ទាំងនេះ នៅពេលអំពើនោះត្រូវបានប្រព្រឹត្តដោយសកម្ម ឬអកម្ម ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ក៏ត្រូវយល់ក្នុងន័យមួយ ក្តោបទាំងការប៉ុនប៉ងប្រព្រឹត្តអំពើពុករលួយផងដែរ ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់ ត្រូវគោរពតាមច្បាប់ និងក្រមសីលធម៌នេះ។ មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវបង្ការ និងប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះអំពើហឹង្សា ឱ្យបានល្អបំផុតតាមសមត្ថភាពរបស់ខ្លួន ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលមានហេតុផលនឹងជឿថាមានការរំលោភបំពាន ឬប្រុងនឹងរំលោភបំពានលើក្រមនេះ ត្រូវរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយប្រសិនជាចាំបាច់ ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញា

ធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

## ***អត្ថាធិប្បាយ :***

ក- ក្រមនេះត្រូវបានគោរពប្រតិបត្តិតាម កាលណាក្រមនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ និងការអនុវត្តជាតិ ។ ប្រសិនបើច្បាប់ និងការអនុវត្តជាតិមានចែងពីបទបញ្ញត្តិតឹងរឹងជាងបទបញ្ញត្តិនៃក្រមនេះ បទបញ្ញត្តិដែលតឹងរឹងនេះ ត្រូវយកមកប្រតិបត្តិតាម ។

ខ- មាត្រានេះ សំដៅរក្សាតុល្យភាពរវាងមួយផ្នែកជាតម្រូវការឱ្យមានបទវិន័យផ្ទៃក្នុងរបស់ស្ថាប័នដែលសុវត្ថិភាពសាធារណៈពឹងអាស្រ័យលើយ៉ាងធំធេង និងមួយផ្នែកទៀតជាតម្រូវការសំរាប់ដោះស្រាយអំពើរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋាន។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវរាយការណ៍ពីការរំលោភបំពាននោះជូនថ្នាក់លើតាមលំដាប់ឋានានុក្រម

ហើយចាត់វិធានការត្រឹមត្រូវតាមច្បាប់ផ្សេងទៀត ដែលនៅក្រៅឋានានុក្រមរបស់ខ្លួន តែនៅពេលណាដែលគ្មានដំណោះស្រាយផ្សេងទៀត ឬដំណោះស្រាយនោះ គ្មានប្រសិទ្ធភាព។ ក្នុងករណីនេះ មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ឬទោសទណ្ឌផ្សេងទៀត ដោយសារតែខ្លួនបានរាយការណ៍ពីការរំលោភបំពានក្រមនេះ ឬជិតនឹងរំលោភបំពានក្រមនេះ។

គ- ពាក្យ "ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ" សំដៅដល់អាជ្ញាធរ ឬស្ថាប័ន ដែលមាននៅក្នុងច្បាប់ជាតិ ទោះជាអាជ្ញាធរ ឬស្ថាប័ននោះស្ថិតនៅក្នុងទីភ្នាក់ងារប្រតិបត្តិច្បាប់ ឬឯករាជ្យក៏ដោយ ឬដោយលក្ខន្តិកៈ ច្បាប់ទំនៀមទំលាប់ ឬការអនុវត្តដទៃទៀត ដើម្បីពិនិត្យលើបណ្តឹងសារទុក្ខ ឬបណ្តឹងផ្សេងទៀត ដែលកើតចេញពីការរំលោភបំពាននានា នៅក្នុងវិសាលភាពនៃក្រមសីលធម៌នេះ ។

ឃ- នៅប្រទេសខ្លះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអាចត្រូវបានចាត់ទុកថាជាការបំពេញភារកិច្ចពិនិត្យបណ្ដឹងប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ច ដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ(គ)ខាងលើ។ ហេតុដូច្នេះ មន្ត្រីប្រតិបត្តិច្បាប់អាចយកការរំលោភបំពាននេះ ទៅផ្សព្វផ្សាយដល់សាធារណៈជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបាន ប្រសិនបើគាត់អាចបង្ហាញមូលហេតុថា នេះជាវិធានការចុងក្រោយ និងស្របទៅតាមច្បាប់ និងទំនៀមទម្លាប់របស់ប្រទេស និងគោរពតាមបញ្ញត្តិនៃមាត្រាទី៨ នៃក្រមសីលធម៌នេះ ។

ង- មន្ត្រីប្រតិបត្តិច្បាប់ ដែលអនុវត្តតាមបញ្ញត្តិនៃក្រមសីលធម៌នេះ សក្តិសមនឹងទទួលបាននូវការគោរព ការគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងកិច្ចសហប្រតិបត្តិការពីសហគមន៍ និងស្ថាប័នរបស់ខ្លួន ព្រមទាំងពីមន្ត្រីប្រតិបត្តិច្បាប់អាជីពផ្សេងទៀត។

~~~~~~~~~
~~~~~~~~~